ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុស្សរណៈយោគយល់

រវាង

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប

ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

និង

អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360)

ស្តីពី

ការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម

សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

**អនុស្សរណៈយោគយល់**

**រវាង**

**លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាម**

**បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)**

**និង**

**អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360)**

**ស្តីពី**

**ការអនុវត្តផែនការការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម**

**សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

**ប្រការ ១. គណនេយ្យភាពសង្គម**

ផែនការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០១៩-២០២៣) បានរៀបចំឡើងដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធរវាងលេខាធិការដ្ឋាន គ.ជ.អ.ប ជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ក្រោមក្របខ័ណ្ឌកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការងារគណនេយ្យភាពសង្គមគឺជាផ្នែកមួយដ៏សំខាន់មួយនៃអភិបាលកិច្ចល្អ និងជាដំណើរការនៃការចូលរួមរវាងប្រជាពលរដ្ឋនិងរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយការស្ថាបនា តាមរយៈការធ្វើសេចក្តីសម្រេចចិត្តជាសាធារណៈ និងអនុវត្តសកម្មភាពនានា។ សកម្មភាពទាំងនោះ រួមបញ្ចូលសកម្មភាពដែលប្រជាពលរដ្ឋ និងតំណាងប្រជាពលរដ្ឋអាចធ្វើការផ្តល់យោបល់សម្រាប់ឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន និងត្រួតពិនិត្យតាមដានពីការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា មន្ត្រី និងអ្នកផ្តល់សេវា នៃសេវារដ្ឋបាលឃុំសង្កាត់ សេវាអប់រំ (សាលាបឋមសិក្សា) សេវាសុខាភិបាល (មណ្ឌលសុខភាព) និងសេវារដ្ឋបាលក្រុង

ស្រុក ខណ្ឌ ក៏ដូចជាសេវាមួយចំនួនទៀត ស្របទៅតាមការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាល ថ្នាក់ក្រោមជាតិ។

**ប្រការ ២. គោលបំណងនៃអនុស្សារណៈយោគយល់** (MoU)

អនុស្សារណៈយោគយល់នេះ មានគោលបំណងដើម្បីកំណត់ពីកាតព្វកិច្ច ការទទួលខុសត្រូវ និងកិច្ចសហប្រតិបត្តិការរបស់ភាគីទាំងពីរគឺ លេខាធិការដ្ឋាន គ.ជ.អ.ប និងអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI360) ដើម្បីអនុវត្តសកម្មភាពផែនការការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងតំបន់គោលដៅ ដូចមានបញ្ជាក់ក្នុងឧបសម្ព័ន្ធទី១ និងទី២ ព្រមទាំងផែនការសកម្មភាព និងថវិកា ដូចមានក្នុងឧបសម្ព័ន្ធទី៣ នៃអនុស្សារណៈយោគយល់នេះ។

អនុស្សារណៈយោគយល់នេះនឹងមានសុពលភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខា រហូតដល់ខែធ្នូ ឆ្នាំ២០២១។ អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI360) នឹងខិតខំប្រឹងប្រែងស្វែងរកថវិកាគាំទ្រការអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គមនៅក្នុងតំបន់គោលដៅ ដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី១ និងទី២ ព្រមទាំងរំពឹងថានឹងមានការពង្រីកតំបន់គោលដៅថ្មី និងសេវាថ្មីៗបន្ថែមទៀត ស្របតាមផែនការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០១៩-២០២៣)។ តំបន់គោលដៅអនុវត្ត និងសេវាផ្សេងៗទៀតនឹងត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ដោយផ្អែកលើការព្រមព្រៀងជាលាយលក្ខណ៍អក្សររបស់ភាគីទាំងពីរ។

**ប្រការ ៣. ការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)**

លេខាធិការដ្ឋាន គ.ជ.អ.ប ព្រមព្រៀងដូចខាងក្រោម៖

១. ផ្តល់ការណែនាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងតំបន់គោលដៅ ស្តីពីខ្លឹមសារនៃអនុស្សារណៈយោគយល់នេះ។

២. ផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សា មន្ត្រីរដ្ឋបាលឃុំ/សង្កាត់ មន្ត្រីជំនាញវិស័យសុខាភិបាល មន្ត្រីជំនាញវិស័យអប់រំ និងវិស័យផ្សេងៗទៀតតាមការកំណត់ជាក់ស្តែងនៅក្នុងតំបន់គោលដៅ អំពីទស្សនទាន ឧបករណ៍ និងដំណើរការនៃការអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គម ជាពិសេសគោលការណ៍អភិបាលកិច្ចល្អ និងខ្សែគណនេយ្យភាព ព្រមទាំង

តួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្នែកតម្រូវការ ដើម្បីលើកកម្ពស់គោលការណ៍ខាងលើ និងគាំទ្រសម្របសម្រួលការអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គម នៅក្នុងតំបន់គោលដៅ។

៣. គាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់ផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4Cs) និងសៀវភៅណែនាំអំពីកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋក្នុងតំបន់គោលដៅ ដោយមានការណែនាំបច្ចេកទេស និង/ឬការតម្រង់ទិសអំពីរបៀបផលិតព័ត៌មាន ការដាក់តាំងបង្ហាញ ផ្សព្វផ្សាយ និងប្រើប្រាស់នៅក្នុងដំណើរការផែនការអនុវត្តគណនេយ្យភាពសង្គម (ផ.អ.គ.ស)។

៤. សហការបណ្តុះបណ្តាលតម្រង់ទិស ដល់មន្ត្រីបង្គោលរបស់អង្គការដៃគូអនុវត្ត (NGOs) ស្តីពីផែនការអនុវត្តគណនេយ្យភាពសង្គម ដើម្បីឱ្យមានភាពស្របគ្នាជាមួយនឹងវគ្គបណ្តុះបណ្តាលបន្តដល់ដៃគូអនុវត្តរបស់ផ្នែកតម្រូវការ តាមបណ្តារដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌគោលដៅ។

៥. ត្រួតពិនិត្យការអនុវត្តជាប្រចាំនូវការបំពេញការងារ ការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សាឃុំ/សង្កាត់ មន្ត្រីជំនាញវិស័យសុខាភិបាល មន្ត្រីជំនាញវិស័យអប់រំ និង វិស័យផ្សេងទៀតតាមការកំណត់ជាក់ស្តែងដែលពាក់ព័ន្ធ ដើម្បីធានាថាការផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋ និងដំណើការដាក់ពិន្ទុដោយផ្នែកទាំងពីរ (អង្គភាពផ្តល់សេវា និងប្រជាពលរដ្ឋ) ក្នុងដំណើរការអនុវត្តផែនការគណនេយ្យភាពសង្គម បានត្រឹមត្រូវពេញលេញ និងស្របតាមវដ្ត នៃសកម្មភាព ផែនការអនុវត្តគណនេយ្យភាពសង្គមប្រចាំឆ្នាំ និងឯកសារណែនាំស្តីពីកិច្ចប្រតិបត្តិការការងារគណនេយ្យភាពសង្គមរបស់ផ្នែកផ្គត់ផ្គង់។

៦. រៀបចំ និងចែករំលែកនូវរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តផែនការគណនេយ្យភាពសង្គម ជារៀងរាល់ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដូចដែលបានឯកភាពគ្នាតាមមាតិកា នៃរបាយការណ៍ដែលមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធទី៥។

៧. សម្របសម្រួល និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ផ្នែកផ្គត់ផ្គង់ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងដំណើរការអនុវត្តការងារគណនេយ្យភាពសង្គមប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ពីមួយឆ្នាំទៅមួយឆ្នាំនៅក្នុងតំបន់គោលដៅដែលបានកំណត់។

**ប្រការ ៤. ការទទួលខុសត្រូវរបស់អង្គការសុខភាពគ្រួសារអន្តរជាតិ** (FHI 360)

អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) ព្រមព្រៀងដូចខាងក្រោម៖

១. ផ្តល់ការណែនាំដល់បុគ្គលិក របស់អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI360) និងអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះកិច្ចសន្យាជាមួយអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI360) ទាក់ទងនឹងខ្លឹមសារនៃអនុស្សារណៈយោគយល់នេះ។

២. ផ្តល់ការបណ្តុះបណ្តាលដល់អង្គការមិនមែនរដ្ឋាភិបាលជាដៃគូអនុវត្ត ដែលបានចុះកិច្ចសន្យាជាមួយអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) អំពីទស្សនទាន ឧបករណ៍ នីតិវិធីដំណើរការនៃគណនេយ្យភាពសង្គម គោលការណ៍អភិបាលកិច្ចល្អ ខ្សែគណនេយ្យភាព និងសារៈសំខាន់នៃការ

ចូលរួមរបស់ប្រជាពលរដ្ឋ ក៏ដូចជាការទទួលខុសត្រូវ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងប្រជាពលរដ្ឋ ក្នុងការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គម ដំណាក់កាលទី២។

៣. ផ្តល់ថវិកាគាំទ្រដល់អង្គការមិនមែនរដ្ឋាភិបាលជាដៃគូអនុវត្ត ដែលបានចុះកិច្ចសន្យាជាមួយអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) សម្រាប់អនុវត្តសកម្មភាពគណនេយ្យភាពសង្គម។

៤. ត្រួតពិនិត្យតាមដានការអនុវត្តជាប្រចាំរបស់ខ្លួន និងអង្គការមិនមែនរដ្ឋាភិបាលជាដៃគូអនុវត្ត ដែលបានចុះកិច្ចសន្យាជាមួយអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) ដើម្បីធានាថាសកម្មភាពគណនេយ្យភាពសង្គមបានអនុវត្តត្រឹមត្រូវពេញលេញ ដោយមានការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្របតាមផែនការអនុវត្តគណនេយ្យភាពសង្គម និងឯកសារស្តីពីកិច្ចប្រតិបត្តិការការងារគណនេយ្យភាពសង្គមរបស់ផ្នែកតម្រូវការ។

៥. រៀបចំ និង ចែករំលែកនូវអនុស្សារណៈយោគយល់ និងផែនការសកម្មភាពប្រចាំឆ្នាំ របស់អង្គការដៃគូអនុវត្ត ដែលបានចុះកិច្ចសន្យាអនុវត្តសកម្មភាពគណនេយ្យភាពសង្គម ជាមួយអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360) ជូនដល់លេខាធិការដ្ឋាន គ.ជ.អ.ប និងរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការសម្របសម្រួល និងកិច្ចសហការគាំទ្រការអនុវត្តសកម្មភាពនានារបស់អង្គការដៃគូអនុវត្តទាំងនោះ។

៦. រៀបចំ និងចែករំលែកនូវរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម ជារៀងរាល់ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដូចដែលបានឯកភាពគ្នាតាមមាតិកា នៃរបាយការណ៍ដែលមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធទី៥។

៧. សហការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ នៃផ្នែកផ្គត់ផ្គង់ក្នុងដំណើរការអនុវត្តផែនការគណនេយ្យភាពសង្គម ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ពីមួយឆ្នាំទៅមួយឆ្នាំនៅក្នុងតំបន់គោលដៅដែលបានកំណត់។

## ប្រការ ៥. ការចាត់ចែងសម្របសម្រួល

ក្នុងករណីចាំបាច់ ភាគីទាំងពីរត្រូវរៀបចំកិច្ចប្រជុំសម្របសម្រួលលើដំណើរការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គម ក្នុងគោលបំណងដូចខាងក្រោម៖

- ពិនិត្យមើលអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៅក្នុងដំណើរការអនុវត្តសកម្មភាពផែនការអនុវត្តគណនេយ្យភាពសង្គម។
- កំណត់ពីបញ្ហាអាទិភាព និងស្វែងរកដំណោះស្រាយប្រកបដោយកិច្ចសហការគ្នា។

លេខាធិការដ្ឋាន

- ពិភាក្សា និងព្រមព្រៀងលើចំណុចកែលម្អក្នុងដំណើរការអនុវត្តដែលបានលើកឡើងដើម្បីដាក់បញ្ចូលទៅក្នុងផែនការអនុវត្តនាពេលអនាគត។
- ពិភាក្សាអំពីបញ្ហាផ្សេងទៀតដែលពាក់ព័ន្ធនឹងការអនុវត្តការងារគណនេយ្យភាពសង្គម។

## ប្រការ ៦. វិសោធនកម្ម ឬការបញ្ចប់អនុស្សារណៈយោគយល់

អនុស្សារណៈយោគយល់នេះ អាចនឹងត្រូវបានធ្វើវិសោធនកម្មនៅពេលណាមួយក្នុងករណីដែលមានការព្រមព្រៀងជាលាយលក្ខណ៍អក្សររបស់ភាគីទាំងពីរ។ ការបញ្ចប់អនុស្សារណៈយោគយល់នេះ នឹងតម្រូវឱ្យមានការជូនដំណឹងជាលាយលក្ខណ៍អក្សរយ៉ាងតិច៨ សប្តាហ៍ និងមានការព្រមព្រៀងពីភាគីទាំងពីរទៅលើវិធានការសមស្រប ដើម្បីធានាឱ្យមានការអនុវត្តការងារគណនេយ្យភាពសង្គម ក្នុងតំបន់គោលដៅ បន្ទាប់ពីការបញ្ចប់អនុស្សារណៈយោគយល់នេះ។

| | **លេខាធិការដ្ឋាន គ.ជ.អ.ប** | **អង្គការសុខភាពគ្រួសារអន្តរជាតិ** (FHI 360) |
|---|---|---|
| ហត្ថលេខា ៖ | | |
| ឈ្មោះ ៖ | *NGAN CHAMROEUN* | សេម សុភា[illegible] |
| មុខងារ ៖ | ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. | តំណាងអង្គការ FHI 360 |
| កាលបរិច្ឆេទ ៖ | 20.04.2020 | 20.04.2020. |

## ឧបសម្ព័ន្ធទី១÷

## តំបន់គោលដៅសម្រាប់អនុវត្តឆ្នាំ២០២០ ដែលកំណត់ក្នុងអនុស្សារណៈរវាងលេខាធិការដ្ឋាន គ.ជ.អ.ប និងអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI360)

| ល.រ | រាជធានី ខេត្ត | ក្រុង | រដ្ឋបាលសង្កាត់ | | សាលាបឋមសិក្សា | | មណ្ឌលសុខភាព | | ប្រភពថវិកា |
|---|---|---|---|---|---|---|---|---|---|
| | | | ចំនួនសង្កាត់សរុប | ចំនួនសង្កាត់អនុវត្ត | ចំនួនសាលាសរុប | ចំនួនសាលាអនុវត្ត | ចំនួនមណ្ឌលសរុប | ចំនួនមណ្ឌលអនុវត្ត | |
| ១ | បន្ទាយមានជ័យ | សិរីសោភ័ណ | ៧ | ៧ | ២៩ | ១៤ | ៨ | ៨ | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) |
| | | ប៉ោយប៉ែត | ៣ | ៣ | ៣៨ | ៦ | ៤ | ៤ | |
| | **សរុប** | **២** | **១០** | **១០** | **៦៧** | **២០** | **១២** | **១២** | |
| ២ | សៀមរាប | សៀមរាប | ១២ | ១២ | ៥២ | ២៤ | ១០ | ១០ | |
| | **សរុប** | **១** | **១២** | **១២** | **៥២** | **២៤** | **១០** | **១០** | |
| ៣ | បាត់ដំបង | បាត់ដំបង | ១០ | ១០ | ៣៦ | ២០ | ៨ | ៨ | |
| | **សរុប** | **១** | **១០** | **១០** | **៣៦** | **២០** | **៨** | **៨** | |
| ៤ | កំពង់ឆ្នាំង | កំពង់ឆ្នាំង | ៤ | ៤ | ៨ | ៨ | ៤ | ៤ | |
| | **សរុប** | **១** | **៤** | **៤** | **៨** | **៨** | **៤** | **៤** | |
| ៥ | កណ្ដាល | តាខ្មៅ | ១០ | ១០ | ២៦ | ២០ | ១០ | ១០ | |
| | **សរុប** | **១** | **១០** | **១០** | **១២** | **១២** | **១០** | **១០** | |
| ៦ | កំពត | កំពត | ៥ | ៥ | ១២ | ១២ | ៥ | ៥ | |
| | **សរុប** | **១** | **៥** | **៥** | **១២** | **១២** | **៥** | **៥** | |
| | **សរុបរួម** | **៦** | **៥១** | **៥១** | **១៨៧** | **៩៦** | **៤៩** | **៤៩** | |

*បញ្ជាក់៖ តំបន់គោលដៅសម្រាប់អនុវត្តឆ្នាំ ២០២០ ខាងលើនេះអាចនឹងមានការប្រែប្រួលក្នុងករណីមានការធ្វើបច្ចុប្បន្នភាពតំបន់គោលដៅអនុវត្ត នៅឆ្នាំបន្តបន្ទាប់ ដោយស្រប តាមការពិភាក្សា និងឯកភាពគ្នារវាងភាគីទាំងពីរ។*

## ឧបសម្ព័ន្ធទី២៖

### តំបន់គោលដៅសម្រាប់អនុវត្តឆ្នាំ២០២០ដល់២០២១ដែលកំណត់ក្នុងអនុស្សរណៈរវាងលេខាធិការដ្ឋាន គ.ជ.អ.ប និងអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI360)

| ល.រ | រាជធានី ខេត្ត | ក្រុង | រដ្ឋបាលសង្កាត់ | | សាលាបឋមសិក្សា | | មណ្ឌលសុខភាព | | ប្រភពថវិកា |
|---|---|---|---|---|---|---|---|---|---|
| | | | ចំនួនសង្កាត់សរុប | ចំនួនសង្កាត់អនុវត្ត | ចំនួនសាលាសរុប | ចំនួនសាលាអនុវត្ត | ចំនួនមណ្ឌលសរុប | ចំនួនមណ្ឌលអនុវត្ត | |
| ១ | បន្ទាយមានជ័យ | សិរីសោភ័ណ | ៧ | ៧ | ២៩ | ១៤ | ៨ | ៨ | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) |
| | | ប៉ោយប៉ែត | ៣ | ៣ | ៣៨ | ៦ | ៤ | ៤ | |
| | **សរុប** | **២** | **១០** | **១០** | **៦៧** | **២០** | **១២** | **១២** | |
| ២ | សៀមរាប | សៀមរាប | ១២ | ១២ | ៥២ | ២៤ | ១០ | ១០ | |
| | **សរុប** | **១** | **១២** | **១២** | **៥២** | **២៤** | **១០** | **១០** | |
| ៣ | បាត់ដំបង | បាត់ដំបង | ១០ | ១០ | ៣៦ | ២០ | ៨ | ៨ | |
| | **សរុប** | **១** | **១០** | **១០** | **៣៦** | **២០** | **៨** | **៨** | |
| ៤ | កំពង់ឆ្នាំង | កំពង់ឆ្នាំង | ៤ | ៤ | ៨ | ៨ | ៤ | ៤ | |
| | **សរុប** | **១** | **៤** | **៤** | **៨** | **៨** | **៤** | **៤** | |
| ៥ | កណ្ដាល | តាខ្មៅ | ១០ | ១០ | ២៦ | ២០ | ១០ | ១០ | |
| | **សរុប** | **១** | **១០** | **១០** | **១២** | **១២** | **១០** | **១០** | |
| ៦ | កំពត | កំពត | ៥ | ៥ | ១២ | ១២ | ៥ | ៥ | |
| | **សរុប** | **១** | **៥** | **៥** | **១២** | **១២** | **៥** | **៥** | |
| | **សរុបរួម** | **៦** | **៥១** | **៥១** | **១៨៧** | **៩៦** | **៤៩** | **៤៩** | |

*__បញ្ជាក់៖__ តំបន់គោលដៅសម្រាប់អនុវត្តឆ្នាំ ២០២០-២០២១ ខាងលើនេះអាចនឹងមានការប្រែប្រួលក្នុងករណីមានការធ្វើបច្ចុប្បន្នភាពតំបន់គោលដៅអនុវត្ត ដោយស្របតាមការពិភាក្សា និងឯកភាពគ្នារវាងភាគីទាំងពីរ។*

## ឧបសម្ព័ន្ធទី៣

**ផែនការសកម្មភាព និងថវិកាគ្រោងសម្រាប់អនុវត្តប្រចាំឆ្នាំ ២០២០ កំណត់ត្រាអនុស្សារណៈរវាងលេខាធិការដ្ឋាន គ.ជ.អ.ប និងអង្គការអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360)**

| ល.រ | សកម្មភាព | សូចនាករ | គោលដៅ | ថវិកា | ប្រភពថវិកា | ស្ថាប័នប្រតិបត្តិ | អង្គការដៃគូ | 2020 | | | | | | | | | | | | Remark |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | 01 | 02 | 03 | 04 | 05 | 06 | 07 | 08 | 09 | 10 | 11 | 12 | |
| **សមាសភាគទី១ ៖ តម្លាភាព ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា** | | | | $ 219,000.00 | | | | | | | | | | | | | | | | |
| ១ | ការផ្សព្វផ្សាយកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ | ១៥០ លើក ចំនួនអ្នកចូលរួម ៤៦០០នាក់ | ក្រុងតាខ្មៅ កំពត កំពង់ឆ្នាំង សៀមរាប ប៉ោយប៉ែត សិរីសោភ័ណ និងបាត់ដំបង | 219,000 | USAID | FHI 360 | អង្គការដៃគូ | | | | | x | x | x | x | | | | | |
| **សមាសភាគទី២ ៖ ការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ** | | | | $ 328,500.00 | | | | | | | | | | | | | | | | |
| ១ | រៀបចំកិច្ចប្រជុំដាក់ពិន្ទុ និងកិច្ចប្រជុំរួម | ៣៥៧ លើក ចំនួនអ្នកចូលរួម ៧២០០នាក់ | ក្រុងតាខ្មៅ កំពត កំពង់ឆ្នាំង សៀមរាប ប៉ោយប៉ែត សិរីសោភ័ណ និងបាត់ដំបង | 328,500 | USAID | FHI 360 | អង្គការដៃគូ | | | | | | | | x | x | x | | | |
| **សមាសភាគទី៣ ៖ ការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម** | | | | $ 25,000.00 | | | | | | | | | | | | | | | | |
| ១ | ការផ្សព្វផ្សាយផែនការ JAAP | ១០០ លើក ចំនួនអ្នកចូលរួម ៣០០០នាក់ | ក្រុងតាខ្មៅ កំពត កំពង់ឆ្នាំង សៀមរាប ប៉ោយប៉ែត សិរីសោភ័ណ និងបាត់ដំបង | 12,000 | USAID | FHI 360 | អង្គការដៃគូ | | | | | | | | | | x | x | x | |
| ២ | កិច្ចប្រជុំគណៈកម្មាធិការ JAAP | ១០០ លើក ចំនួនអ្នកចូលរួម 500នាក់ | ក្រុងតាខ្មៅ កំពត កំពង់ឆ្នាំង សៀមរាប ប៉ោយប៉ែត សិរីសោភ័ណ និងបាត់ដំបង | 13,000 | USAID | FHI 360 | អង្គការដៃគូ | | | | | | | | | x | x | x | x | |
| **សមាសភាគទី៤ ការបណ្តុះបណ្តាល អភិវឌ្ឍន៍សមត្ថភាព និងការទំនាក់ទំនង** | | | | $ 20,000.00 | | | | | | | | | | | | | | | | |
| ១ | វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពបុគ្គលិកអង្គការដៃគូ | ២ លើក ចំនួនអ្នកចូលរួម ២៥នាក់ | ភ្នំពេញ | 4,000 | USAID | FHI 360 | FHI 360 | | | | x | | x | | | | | | | |
| ២ | វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពអ្នកសម្របសម្រួលគណនេយ្យភាពសង្គម | ៣ លើក ចំនួនអ្នកចូលរួម ១១០ នាក់ | ក្រុងតាខ្មៅ កំពត កំពង់ឆ្នាំង សៀមរាប ប៉ោយប៉ែត សិរីសោភ័ណ និងបាត់ដំបង | 16,000 | USAID | FHI 360 | អង្គការដៃគូ | | | | | x | | x | | x | | | | |
| **សមាសភាគទី៥ ៖ ការគ្រប់គ្រងគម្រោង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** | | | | $ 49,000.00 | | | | | | | | | | | | | | | | |
| ១ | មន្រ្តីគម្រោងត្រួតពិនិត្យ ការអនុវត្តរបស់អង្គការដៃគូ | ១៦០ លើក ចំនួនអ្នកចូលរួម ២៥ នាក់ | ក្រុងតាខ្មៅ កំពត កំពង់ឆ្នាំង សៀមរាប ប៉ោយប៉ែត សិរីសោភ័ណ និងបាត់ដំបង | 10,000 | USAID | FHI 360 | FHI 360 | | | | x | x | x | x | x | x | x | x | x | |
| ២ | អង្គការដៃគូត្រួតពិនិត្យ និងបង្ហាត់បង្ហាញអ្នកសម្របសម្រួលគណនេយ្យភាពសង្គម | ៥០០ លើក ១១០នាក់ | ក្រុងតាខ្មៅ កំពត កំពង់ឆ្នាំង សៀមរាប ប៉ោយប៉ែត សិរីសោភ័ណ និងបាត់ដំបង | 39,000 | USAID | FHI 360 | អង្គការដៃគូ | | | | x | x | x | x | x | x | x | x | x | |
| សរុបរួម | | | | $ 641,500.00 | | | | | | | | | | | | | | | | |

*បញ្ជាក់៖ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ២០២០ ខាងលើនេះអាចនឹងមានការប្រែប្រួលក្នុងករណីមានការធ្វើបច្ចុប្បន្នភាពផែនការសកម្មភាព និងថវិកា នៅឆ្នាំបន្ទាប់ ដោយស្របតាមការពិភាក្សា និងឯកភាពគ្នារវាងភាគីទាំងពីរ។*

លេខាធិការដ្ឋាន

## ឧបសម្ព័ន្ធទី៤÷

## ថវិកាគ្រោងសម្រាប់អនុវត្តប្រចាំឆ្នាំ ២០២០ ដល់ ២០២១ ដែលកំណត់ក្នុងអនុស្សារណៈរវាងលេខាធិការដ្ឋាន គ.ជ.អ.ប និងអង្គការអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI360)

| ល.រ | សមាសភាគ | ២០២០-២០២១(USD) | ២០២០(USD) | ២០២១(USD) |
|---|---|---|---|---|
| ១ | សមាសភាគទី១៖ តម្លាភាព ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា | ៤០៩.000 | ២១៩.000 | ១៩០.000 |
| ២ | សមាសភាគទី២៖ ការត្រួតពិនិត្យ តាមដានដោយប្រជាពលរដ្ឋ | ៦២៨.៥00 | ៣២៨.៥00 | ៣00.000 |
| ៣ | សមាសភាគទី៣៖ ការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម | ៤៥.000 | ២៥.000 | ២0.000 |
| ៤ | សមាសភាគទី៤៖ ការបណ្តុះបណ្តាល អភិវឌ្ឍសមត្ថភាព និងការទំនាក់ទំនង | ៤0.000 | ២0.000 | ២0.000 |
| ៥ | សមាសភាគទី៥ ៖ ការគ្រប់គ្រង ត្រួតពិនិត្យតាមដាន និងវាយតម្លៃ | ៩៨.000 | ៤៩.000 | ៤៩.000 |
| ៦ | ផ្សេងៗ | | | |
| | ថវិកាគ្រោងសរុប | ១.២២0.៥00 | ៦៤១.៥00 | ៥៧៩.000 |

*<u>បញ្ជាក់៖</u> ថវិកាគ្រោងប្រចាំឆ្នាំសម្រាប់អនុវត្តឆ្នាំ ២០២០ និង ២០២១ ខាងលើអាចនឹងមានការផ្លាស់ប្តូរក្នុងករណីចាំបាច់ ដោយស្របតាមការពិភាក្សា និងឯកភាពរវាងភាគីទាំងពីរ*

ឧបសម្ព័ន្ធទី៥÷

## មាតិការបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម

១. សេចក្តីផ្តើម

២. វឌ្ឍនៈភាពនៃការអនុវត្ត

៣. បញ្ហាប្រឈម និងដំណោះស្រាយ

៤ ស្ថានភាពហិរញ្ញវត្ថុ

៥. សំណូមពរ និងអនុសាសន៍

៦. សេចក្តីសន្និដ្ឋាន